Department of Primary Industries

បណ្ណព័ត៌មាន 4

# រក្សាវាឲ្យបានស្អាតសំរាប់ទីវាលដាំបន្លែ

## ប្រភពនៃសត្វចង្រៃ និងជម្ងឺដែលពុំមែនជារុក្ខជាតិ

Virginia Brunton & Jeremy Badgery-Parker, Ourimbah

### ប្រភពនៃសត្វចង្រៃ

បន្ថែមពីលើរុក្ខជាតិដែលជាប្រភពនៃសត្វចង្រៃ មនុស្ស និងវត្ថុទាំងអស់ក៏អាចជាប្រភពនៃសត្វល្អិតចង្រៃ និងជម្ងឺបានដែរ។

**មនុស្សទាំងឡាយ** (អ្នកធ្វើការ និងអ្នកមកទស្សនាទាំងពីរ) អាចជាប្រភពនៃសត្វល្អិតចង្រៃ និងជម្ងឺ ប្រសិនបើអនាម័យល្អរបស់ចំការ និងការដាក់ឲ្យនៅដាច់ពីគេដើម្បីបង្ការរោគពុំបានធ្វើតាមទេ។ មនុស្សដែលចូល និងទៅមកជុំវិញកន្លែងផលិតភោគផលរបស់លោកអ្នក អាចជាប្រព័ន្ធដឹកជញ្ជូនសំរាប់សត្វចង្រៃ។ សត្វចង្រៃអាចបន្តនៅលើសម្លៀកបំពាក់ ដៃមនុស្ស និងជាពិសេសស្បែកជើង។ មនុស្សពុំគ្រាន់តែអាចនាំសត្វល្អិតចង្រៃ និងជម្ងឺមកក្នុងដំណាំប៉ុណ្ណោះទេ ក៏ប៉ុន្តែអាចនាំយកវាទៅជុំវិញខាងក្នុងដំណាំផងដែរ។

**យានយន្ត ត្រាក់ទ័រ និងឧបករណ៍ធ្វើចំការ** អាចដឹកជញ្ជូនសត្វចង្រៃ និងជម្ងឺ ហើយជាញឹកញាប់ត្រូវបានគេមើលស្រាល នៅពេលគិតពិចារណាអំពីកន្លែងដែលសត្វល្អិតចង្រៃ សត្វព្រូន និងជម្ងឺអាចចេញមក ក៏ប៉ុន្តែអាចជាប្រភពសំខាន់នៃបញ្ហា។ កំទេចសំណល់រុក្ខជាតិ និងដី គឺជាមធ្យោបាយសំខាន់ដែលសត្វចង្រៃបន្តធ្វើចលនាលើយានយន្ត ត្រាក់ទ័រ និងឧបករណ៍ធ្វើចំការ។ គ្រឿងបរិក្ខារដែលគេធ្លាប់ប្រើពីមុនហើយ ក៏អាចនាំមកនូវសត្វចង្រៃ ជម្ងឺ និងរុក្ខជាតិតូចៗឥតប្រយោជន៍ថ្មីៗបានដែរ។

**គំនរសំរាម** អាចជាបញ្ហានៅលើចំការជាច្រើន។ សំរាម ជាញឹកញាប់ បានឆ្លងតាមដី និងកំទេចសំណល់រុក្ខជាតិដែលអាចផ្តល់ជាកន្លែងជ្រកកោនដល់សត្វចង្រៃ។ គំនរសំរាមក៏ផ្តល់ការការពារដល់សត្វល្អិតចង្រៃ និងជម្ងឺទាំងនេះដែរ ធ្វើឲ្យវានៅរស់បានយូរ និងផ្តល់ឱកាសដល់វាកាន់តែច្រើនដើម្បីចូលទៅក្នុងដំណាំរបស់លោកអ្នក។

**ឧបករណ៍** ដូចជាកន្ត្រៃកាត់មែកឈើ កូនចបកាប់ និងដង្កៀប ហើយសូម្បីតែទូរស័ព្ទចល័តក្តី ក៏អាចនាំជម្ងឺទៅក្នុង និងជុំវិញចំការបានដែរ។

**វត្ថុធាតុទាំងដុំដែលគេលាយជាមួយដី ដើម្បីកែប្រែគុណភាពដី** អាចជាប្រភពនៃសត្វចង្រៃ។ វត្ថុធាតុសរីរាង្គដូចជាជីអំពុក និងជីលាមកសត្វគឺជាហានិភ័យកំរិតខ្ពស់។ វត្ថុធាតុដែលពុំមែនជាសរីរាង្គដូចជាម្នាងសិលា និងកំបោរអាចជាទូទៅ ត្រូវបានចាត់ទុកថាពុំមានជម្ងឺឡើយ នៅពេលគេប្រគល់វាឲ្យ ក៏ប៉ុន្តែប្រសិនបើទុកវាចោលដោយពុំមានអ្វីគ្របបិទបាំង វាអាចមានគ្រាប់រុក្ខជាតិតូចៗ ឬគ្រាប់ស្មៅឥតប្រយោជន៍កាន់តែច្រើនឡើង។



*វត្ថុធាតុសរីរាង្គទាំងដុំ ដែលផ្ទួរលុងគឺ*
*ជាហានិភ័យកំរិតខ្ពស់នៃជម្ងឺរលួយឫសរុក្ខជាតិ*

### ដី

ការដាំដុះនៅក្នុងដីអាចជាការលំបាកយ៉ាងខ្លាំង ប្រសិនបើដំណាំដូចគ្នានេះត្រូវបានដាំហើយដាំទៀត។ សត្វចង្រៃបំផ្លាញដំណាំជាច្រើនមានរួមទាំងជម្ងឺ សត្វព្រូន សត្វល្អិត សត្វចៃ និងរុក្ខជាតិតូចៗឥតប្រយោជន៍ មានដំណាក់កាលនៃជីវិតរស់នៅវិលចុះឡើងដែលសម្របតាម ដើម្បីនៅរស់ឲ្យបានរយៈពេលយូរក្នុងដីគ្មានដំណាំ ដែលសត្វចង្រៃយកធ្វើជាកន្លែងលូតលាស់។

ប្រភពមួយចំនួនធំ ចាំបាច់ត្រូវធ្វើវិនិយោគន៍ក្នុងការធ្វើឲ្យប្រាកដថាដីមានសុខភាពល្អ ជីវិតរស់នៅវិលចុះឡើងរបស់សត្វចង្រៃត្រូវបានបង្អាក់ (ឧទាហរណ៍ ជាមួយនឹងការដាំដំណាំឆ្លាស់គ្នាតាមរដូវ) ហើយលក្ខណៈជីវសាស្ត្រ គីមី និងរាងកាយនៃដីសមរម្យសំរាប់ដំណាំដែលលោកអ្នកកំពុងដាំ។ ការនេះមានរាប់បញ្ចូលទាំងការគ្រប់គ្រងលើជីរដាក់ដំណាំ និងការបាញ់ស្រោចទឹកដោយប្រុងប្រយ័ត្ន និងការរក្សាទុកសារធាតុសរីរាង្គឲ្យមានកំរិតគ្រប់គ្រាន់ក្នុងដី។

*“ត្រូវដាំគ្រាប់ពូជ ឬកូនរុក្ខជាតិតូចៗនៅក្នុងកន្លែងដាំបណ្ដុះស្អាត ដែលពុំមានដាំដំណាំអម្បូរដូចគ្នានឹងដំណាំ (ឬនាំមកនូវជម្ងឺដុះផ្សិត ដែលជារឿយៗបង្ករឡើងដោយដីដូចជាជម្ងឺ* sclerotinia *ជាដើម) ដែលដាំនៅឆ្នាំមុន”*

ការបង្ហូរទឹកចេញអន់ថយ ដែលបណ្ដាលឲ្យទឹកហូរហៀរមកខាងក្រៅ ចូលក្នុងដំណាំក្នុងអំឡុងពេលមានព្យុះភ្លៀង អាចនាំជម្ងឺចូលមកបាន។ ទឹកខ្ទាតសាចទៅក្នុងដំណាំ មកពីទឹកភ្លៀងដែលធ្លាក់បុកទៅលើដីបណ្ដាលមកពីសកម្មភាពត្រាក់ទ័រ ឬយានយន្តដែលបើកបរលើថ្លុកទឹក ក៏ជារបៀបឆ្លងរាលដាលជម្ងឺដែរ។ ទឹកជំនន់តូចតាចក៏អាចបណ្ដាលឲ្យមានជាបញ្ហាធំបានដែរ។

ការប្រើជីអំពុកអាចធ្វើឲ្យសុខភាពដីបានប្រសើរឡើង និងបានបង្ហាញថាមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងជម្ងឺមួយចំនួន ដែលបង្ករឡើងដោយដីដូចជា verticillium (ជម្ងឺដុះផ្សិតប្រភេទម្យ៉ាង) ជាដើម។

ពេលមានសត្វចង្រៃសំខាន់ ជាពិសេសមានបញ្ហាជម្ងឺដីអាចចាំបាច់ត្រូវសម្លាប់មេរោគដោយប្រើឧស្ម័នគីមី។ ប្រសិនបើដីចាំបាច់ត្រូវសម្លាប់មេរោគដោយប្រើឧស្ម័នគីមី គេត្រូវប្រើអ្នកធ្វើការងារក្រោមកិច្ចសន្យាដែលមានការបញ្ជាក់អះអាងជាផ្លូវការ។ យកគ្រឿងបរិក្ខារ និងសម្ភារៈចេញពីទីកន្លែង ហើយយកដំណាំចាស់ៗចេញឲ្យបានច្រើនបំផុត តាមលទ្ធភាពធ្វើបាន បន្ទាប់មកភ្ជួររាស់កប់កាកសំណល់ដំណាំឲ្យបានហ្មត់ចត់ល្អ។ ទុកពេលគ្រប់គ្រាន់ដើម្បីឲ្យកំទេចសំណល់ដំណាំរលួយ បើពុំនោះទេ ការសម្លាប់មេរោគដោយប្រើឧស្ម័នគីមីអាចពុំមានប្រសិទ្ធិភាព។ មិនត្រូវប្រើឧស្ម័នគីមីសម្លាប់មេរោគលើដីដែលត្រជាក់ពេក សើមពេក ឬស្ងួតពេកឡើយ។



*ដីនៅក្នុងផុង ស្បែកជើងកវែង និងវត្ថុទាំងឡាយឯទៀត គឺជាហានិភ័យនៃជម្ងឺរលួយឫសរុក្ខជាតិ*

**ទឹក** អាចផ្ទុកជម្ងឺបានច្រើន ជាពិសេសបាក់តេរីនៃជម្ងឺដុះផ្សិតធ្វើឲ្យរលួយឫសរុក្ខជាតិ។ ទឹកទាំងអស់ដែលសំរាប់ប្រើបាញ់ស្រោចលើដំណាំ លាងសំអាត និងធ្វើឲ្យត្រជាក់ផលដំណាំអាចជាហានិភ័យ ដែលត្រូវត្រួតពិនិត្យដោយប្រុងប្រយ័ត្ន។ ទឹកក្នុងអាងដែលគេផលិតឡើងវិញគឺជាហានិភ័យកំរិតខ្ពស់ដោយការផ្ទុកជម្ងឺ ហើយគួរតែសម្លាប់មេរោគមុននឹងប្រើប្រាស់វា។ ទឹកចេញពីរន្ធដី តាមធម្មតា ពុំមានជម្ងឺរុក្ខជាតិឡើយ ក៏ប៉ុន្តែគួរធ្វើតេស្តដើម្បីឲ្យដឹងប្រាកដច្បាស់។

ការទទួលស្គាល់: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ បានរៀបចំចេញពីរក្សាវាឲ្យបានស្អាត – កាត់បន្ថយការចំណាយ និងការខាតបង់ក្នុងការគ្រប់គ្រងសត្វចង្រៃ និងជម្ងឺនៅក្នុងរោងដាំបន្លែ និងកូនរុក្ខជាតិ។ Badgery-Parker, J and T Burfield 2009 ជាមួយនឹងគំនិត និងឱវាទបានមកពី Sandra McDougall និង Alison Anderson។

© រដ្ឋញូវសៅវែល តាមរយៈក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ ឆ្នាំ២០១០។ លោកអ្នកអាចចម្លង ចែកចាយ និងដោះស្រាយជាមួយនឹងការបោះពុម្ពផ្សាយតាមរបៀបផ្សេងពីនេះដោយសេរី ដើម្បីគោលបំណងណាមួយ គឺឲ្យតែលោកអ្នកបានបញ្ជាក់ថាក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ គឺជាម្ចាស់កម្មសិទ្ធិនៃការបោះពុម្ពផ្សាយនេះ។

ISSN 1832-6668

ការប្រកាសមិនទទួលខុសត្រូវ: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺសំអាងលើចំណេះដឹង និងការយល់ដឹងនៅក្នុងពេលកំពុងសរសេរ (ខែមីនា ឆ្នាំ២០១២)។ ទោះជាយ៉ាងនេះក្ដី ដោយសារការជឿនលឿនផ្នែកចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកអំពីសេចក្ដីត្រូវការដើម្បីឲ្យប្រាកដច្បាស់ថា ពត៌មានដែលគេពឹងផ្អែកទៅលើមានលក្ខណៈទាន់ពេល និងសំរាប់ឆែកមើលបច្ចុប្បន្នភាពនៃពត៌មានជាមួយភ្នាក់ងារសមស្របរបស់ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ឬអ្នកផ្ដល់ឱវាទឯករាជ្យសំរាប់អ្នកប្រើប្រាស់។

ចុះផ្សាយដោយក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ដែលជាផ្នែកមួយរបស់ក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ។

Trim reference INT 12/24527

ការផលិតប័ណ្ណពត៌មាននេះ និងការបកប្រែភាសាបានទទួលការផ្គត់ផ្គង់ប្រាក់មួយចំណែកពីគំរោងដែលទទួលប្រាក់ឧបត្ថម្ភរបស់ HAL អង្គការដំណាំវប្បកម្មអូស្ត្រាលី): *ការដោះស្រាយអំពីគុណភាព និងសុវត្ថិភាពនៃផលិតផលជាមួយអ្នកដាំដុះនៃឧស្សាហកម្មបន្លែ ដែលនិយាយភាសាក្រៅពីភាសាអង់គ្លេស* ារផ្ដើមគំនិតនៃកម្មវិធីអភិវឌ្ឍន៍ឧស្សាហកម្មបន្លែ។